# វិទ្យាស្ថាន ស្លឹករឹត

បូជនីយដ្ឋានសម្រាប់រំឭកដល់អតីតកាល
មជ្ឈមណ្ឌលអប់រំពីអំពើប្រល័យពូជសាសន៍ និងសិទ្ធិមនុស្ស
និងគ្រឹះស្ថានសិក្សាសម្រាប់អនាគត





# សេចក្តីផ្តើម

*វិទ្យាស្ថានស្លឹករឹត គឺជាគម្រោងដ៏មោះមុត និងពោរពេញដោយមហិច្ឆតាក្នុងការផ្សះផ្សានូវការបំផ្លិចបំផ្លាញពីការរាតត្បាតនៃអំពើប្រល័យពូជសាសន៍ក្នុងរយៈពេលប្រមាណបួនឆ្នាំនៃរបបខ្មែរក្រហមមកលើកេរដំណែលវប្បធម៌ដែលមានអាយុកាលរាប់រយសតវត្សរ៍របស់ប្រទេសកម្ពុជា។*

ការផ្សះផ្សាផ្តោតសំខាន់ទៅលើយុត្តិធម៌ ការចងចាំ និងការព្យាបាលរបួសពីអតីតកាល។ វិទ្យាស្ថានស្លឹករឹត នឹងដាក់បញ្ចូលគ្នាតែមួយនូវគ្រឹះស្ថានដែលមានមុខងារផ្សេងៗគ្នា រួមមាន សារមន្ទីរនៃការចងចាំ មជ្ឈមណ្ឌលស្រាវជ្រាវ គ្រឹះស្ថានឧត្តមសិក្សាដែលផ្តោតលើឧក្រិដ្ឋកម្មឃោរឃៅ បណ្ណសារដ្ឋាននៃឯកសារទាក់ទងនឹងរបបខ្មែរក្រហម ព្រមទាំងបណ្ណាល័យស្រាវជ្រាវ ក៏ដូចជាមជ្ឈមណ្ឌលព័ត៌មាន។ លោក ឆាំង យុ ជាសកម្មជនសិទ្ធិមនុស្សម្នាក់ដែលមិនចេះរាថយ ហើយត្រូវបានទទួលស្គាល់ជាសកលថាជាអ្នកស្រាវជ្រាវ និងបង្កើតនូវបណ្ណសារដ្ឋានទាក់ទងនឹងអំពើឃោរឃៅនៃរបបខ្មែរក្រហម។ ជាងនេះទៅទៀត លោកក៏ជាជនរងគ្រោះផ្ទាល់ម្នាក់នៃរបបខ្មែរក្រហម។ ទស្សនវិស័យរបស់លោក គឺធ្វើឲ្យវិទ្យាស្ថានស្លឹករឹតក្លាយជាមជ្ឈមណ្ឌលអន្តរជាតិមួយសម្រាប់ការត្រិះរិះការព្យាបាលរបួសពីអតីតកាល ការផ្សះផ្សា និងការអប់រំ ដើម្បីបំភ្លឺ និងផ្តល់ផលប្រយោជន៍ដល់ប្រជាជនកម្ពុជា ក៏ដូចជាទេសចររាប់លាននាក់ដែលមកដល់ប្រទេសកម្ពុជាជារៀងរាល់ឆ្នាំ។ គោលគំនិតចម្បងនៃវិទ្យាស្ថានស្លឹករឹត គឺរំឭកដល់ជនរងគ្រោះនៃអតីតកាលតាមរយៈការកសាងនូវអនាគតដ៏ត្រចះត្រចង់។



# ឧបសគ្គ

*អស់រយៈពេលជាង៣៥ឆ្នាំ ប្រជាជនកម្ពុជាបានចូលរួមនៅក្នុងកិច្ចខិតខំប្រឹងប្រែងដ៏យូរអង្វែង និងខ្លោចផ្សា ដើម្បីព្យាបាលរបួសបន្សល់ពីរបបខ្មែរក្រហម និងបានកសាងឡើងវិញនូវសង្គម វប្បធម៌ និងរាជរដ្ឋាភិបាលរបស់ខ្លួន។ របបខ្មែរក្រហមបានសម្លាប់អ្នកដែលមានចំណេះដឹង សិល្បករ អ្នកជំនាញ និងប្រជាជនកម្ពុជា តាមរយៈការធ្វើទារុណ្ឌកម្ម ការបង្អត់អាហារ និងការសម្លាប់ ដែលបង្កឲ្យមានការបំផ្លាញយ៉ាងដំណំទៅលើការអភិវឌ្ឍន៍ធនធានមនុស្សរបស់កម្ពុជា។*

នៅប៉ុន្មានទសវត្សរ៍ចុងក្រោយនេះ ប្រជាជនកម្ពុជាបានស្វះស្វែងរកវិធីសាស្ត្រចាំបាច់ជាច្រើន ដើម្បីថែរក្សាការចងចាំអំពីអតីតកាល ការអប់រំខ្លួនឯង និងបណ្តុះបណ្តាលអ្នកដឹកនាំសម្រាប់ថ្ងៃអនាគត ស្របពេលនឹងការបង្កើតនូវសង្គមសន្តិភាព និងយុត្តិធម៌មួយ ដែលវប្បធម៌ និងគំនិតផ្តួចផ្តើមរបស់កម្ពុជាអាចរីកចម្រើនទៅមុខបាន។ កិច្ចខិតខំប្រឹងប្រែងនេះទើបតែសម្រេចបាននូវផ្នែកខ្លះតែប៉ុណ្ណោះ។ ជាក់ស្តែង បូជនីយដ្ឋានរំឭកដល់ការចងចាំបានបង្ហាញអំពីអំពើឃោរឃៅព្រៃផ្សៃដែលបានកើតឡើងនៅចុងទសវត្សរ៍ឆ្នាំ១៩៧០ ប៉ុន្តែមិនបានបង្ហាញអំពីប្រវត្តិសាស្ត្រដ៏យូរលង់ និងថ្លៃថ្លារបស់កម្ពុជានាកាលនោះឡើយ។

មកទល់នឹងបច្ចុប្បន្ន ការតស៊ូប្រឆាំងនឹងការកកើតឡើងវិញនៃឧក្រិដ្ឋកម្មឃោរឃៅមិនទាន់បានលុបបំបាត់ឬកាត់បន្ថយទាំងស្រុងនៅឡើយទេ។ ឧក្រិដ្ឋកម្មឃោរឃៅទាំងនោះនៅតែបន្តរាតត្បាត និងកើតមានឡើងនៅក្នុងប្រទេសស៊ីរី  អ៊ីរ៉ាក់ ដាហ្វួ និងភូមា។ ហេតុដូច្នេះ វិទ្យាស្ថានស្លឹករឹតនឹងពង្រីកការងាររបស់ខ្លួនលើសពីការលើកកម្ពស់ការយល់ដឹងតាមរយៈការស្រាវជ្រាវ និងកម្មវិធីសិក្សាកម្រិតឧត្តមសិក្សាអំពីមនោគមវិជ្ជាបោកបញ្ឆោតនៃការជ្រើសរើសមនុស្សឲ្យចូលរួមប្រព្រឹត្តឧក្រិដ្ឋកម្មឃោរឃៅ ដែលបានតម្រង់លើយុវជនក្មេងៗ តាមរយៈការឃោសនាដោយឈរលើគោលការណ៍ជាតិពន្ធុ នយោបាយ និងការជុសខាត់ស្មារតី។

កម្មវិធីសិក្សានេះនឹងផ្តោតលើវិធីសាស្ត្រនៃការវិភាគ និងឆ្លើយតបទៅនឹងការឃោសនា ដើម្បីធ្វើយ៉ាងណាឲ្យយុវជនអាចផ្តាច់ចេញពីភាពងប់ងល់ និងគតិនិយម ព្រមទាំងបំពាក់បំប៉នដល់យុវជនឲ្យចេះវិភាគ និងប្រើប្រាស់គំនិត និងស្មារតីប្រកបដោយការត្រិះរិះពិចារណា។ វិទ្យាស្ថានស្លឹករឹតរំពឹងថានឹងចែករំលែកនូវការស្រាវជ្រាវ និងកម្មវិធីសិក្សារបស់ខ្លួនឲ្យស្របទៅនឹងអាយុ និងកម្រិតយល់ដឹងរបស់មនុស្ស ដោយបញ្ជ្រាបចូលក្នុងប្រព័ន្ធអប់រំរបស់កម្ពុជា និងចែករំលែកដល់ប្រទេសជិតខាងនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ និងប្រទេសដទៃទៀត ។

> “
>
> *កម្ពុជាមិនអាចគេចវេះពីប្រវត្តិសាស្ត្ររបស់ខ្លួនបានទេ ប៉ុន្តែកម្ពុជាក៏មិនចាំបាច់ស្ថិតនៅជាទាសករនៃប្រវត្តិសាស្ត្ររបស់ខ្លួនឯងនោះដែរ។*
>
> ឆាំង យុ

# មជ្ឈមណ្ឌលឯកសារកម្ពុជា

## ការធ្វើឲ្យប្រសើរឡើងនូវការគោរពសិទ្ធិមនុស្ស យុត្តិធម៌ និងភាពរីកចម្រើននៅក្នុងប្រទេសកម្ពុជា

វិទ្យាស្ថានស្លឹករឹតត្រូវបានផ្តួចផ្តើមឡើងដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលជាអង្គការក្រៅរដ្ឋាភិបាលកម្ពុជាមួយមានទីតាំងនៅរាជធានីភ្នំពេញ។ នៅពេលដែលវិទ្យាស្ថានស្លឹករឹតលេចចេញជារូបរាងទាំងស្រុងមជ្ឈមណ្ឌលឯកសារកម្ពុជានឹងក្លាយទៅជាផ្នែកមួយរបស់វិទ្យាស្ថានស្លឹករឹត។

មជ្ឈមណ្ឌលឯកសារកម្ពុជាត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ១៩៩៥ ដោយអ្នកស្រាវជ្រាវរបស់សាកលវិទ្យាល័យ យ៉េល ដើម្បីធ្វើការប្រមូលចងក្រងឯកសារដើម និងភ័ស្តុតាងដែលជាប់ទាក់ទងដោយផ្ទាល់ទៅនឹងរបបខ្មែរក្រហម ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩។ ពីរឆ្នាំក្រោយមក ពោលគឺនៅឆ្នាំ១៩៩៧ មជ្ឈមណ្ឌលឯកសារកម្ពុជា បានក្លាយទៅជាស្ថាប័ននីតិបុគ្គលឯករាជ្យ។  បើទោះជាបណ្ណសារ ដែលបច្ចុប្បន្នមានឯកសារសរុបជាងមួយលានទំព័រ និងគ្របដណ្តប់ស្ទើរគ្រប់រឿងរ៉ាវដែលបានកើតឡើងនៅក្នុងរបបខ្មែរក្រហមក៏ពិតមែន ក៏ការផ្តោតចម្បងរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា សំដៅដល់ការចងក្រងឯកសារស្តីអំពីឧក្រិដ្ឋកម្មឃោរឃៅ និងការបំពានសិទ្ធិមនុស្សដែលប៉ះពាល់ដល់ប្រជាជនកម្ពុជាស្លូតត្រង់។ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានពឹងផ្អែកយ៉ាងខ្លាំងទៅលើឯកសារភ័ស្តុតាង និងការគាំទ្រពីបណ្ណសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដើម្បីកាត់ទោសមេដឹកនាំជាន់ខ្ពស់នៃរបបខ្មែរក្រហម។

*ជាង២០ឆ្នាំកន្លងមកនេះ ភ្នាក់ងារសហរដ្ឋអាម៉េរិក សម្រាប់ការអភិវឌ្ឍអន្តរជាតិ ក៏ដូចជារដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាលដទៃទៀតនៅជុំវិញសកលលោក បានគាំទ្រការងាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា។*

ក្នុងអំឡុងពេល២០ឆ្នាំកន្លងមកនេះ មជ្ឈមណ្ឌលឯកសារកម្ពុជា បានកសាងនូវបណ្ណសារដ្ឋានឯកសារដើមដ៏ធំបំផុតមួយ និងឯកសារដទៃទៀតដែលទាក់ទងនឹងរបបខ្មែរក្រហម។ មិនតែប៉ុណ្ណោះ មជ្ឈមណ្ឌលឯកសារកម្ពុជា ក៏បានបោះពុម្ពផ្សាយនូវសៀវភៅប្រវត្តិសាស្ត្រខ្មែរក្រហម ដែលត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយនៅតាមគ្រឹះស្ថានសិក្សារបស់រដ្ឋ ព្រមទាំងបានរៀបចំសៀវភៅណែនាំ និងកម្មវិធីសិក្សាសម្រាប់គ្រូបង្រៀន ដែលគ្រូបង្រៀនទាំងនោះបានបង្ហាត់បង្ហាញដល់យុវជនកម្ពុជារាប់ម៉ឺននាក់ ហើយក្នុងនោះមានយុវជនមួយចំនួនបានចូលបម្រើការងារផ្សេងៗគ្នា រួមមានជំនាញផ្នែកច្បាប់ រាជរដ្ឋាភិបាល និងផ្នែកអប់រំ។ បណ្ណសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានវិវត្តទៅជាប្រភពធនធានដែលទទួលស្គាល់ជាសកលសម្រាប់សកម្មជនសិទ្ធិមនុស្ស អ្នកស្រាវជ្រាវ និងអ្នកឯកទេសនៅជុំវិញពិភពលោក។ គណៈគ្រប់គ្រងរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានកសាងអង្គភាពនេះឡើងដោយឈរលើមូលដ្ឋានគ្រឹះហិរញ្ញវត្ថុ ដ៏រឹងមាំ តម្លាភាព និងស្អាតស្អំ។ មជ្ឈមណ្ឌលឯកសារកម្ពុជាបានធ្វើការពិនិត្យ និងគ្រប់គ្រងលើវិភាគទាននៃធនធានដ៏មានតម្លៃដែលបានបរិច្ចាគដោយពុំឲ្យមានការជាប់ពាក់ព័ន្ធនឹងអំពើពុករលួយដែលកំពុងរាតត្បាតនៅក្នុងតំបន់។

មជ្ឈមណ្ឌលឯកសារកម្ពុជា បានបង្កើតគំរូដែលអាចប្រើប្រាស់បាននៅទីដាច់ស្រយាល ដើម្បីចងក្រងឯកសារទាក់ទងនឹងឧក្រិដ្ឋកម្មដ៏ឃោរឃៅ។ មជ្ឈមណ្ឌលឯកសារកម្ពុជាក៏បានធ្វើការវិនិយោគនៅទូទាំងប្រទេសទៅលើការអប់រំ និងបង្កើតនូវអ្នកដឹកនាំសម្រាប់ថ្ងៃអនាគត។ វិទ្យាស្ថានស្លឹករឹត គឺជាជំហានបន្ទាប់សម្រាប់ដោះស្រាយនូវតម្រូវការរបស់កម្ពុជានាពេលបច្ចុប្បន្ន និងអនាគត។ តម្រូវការនៃការព្យាបាលរបួសពីអតីតកាល ការទទួលបានព័ត៌មាន ការកសាងឡើងវិញ និងការដោះស្រាយឧក្រិដ្ឋកម្មឃោរឃៅដែលបានកើតឡើង ទាមទារឲ្យមានទស្សនទានដែលសកម្ម និងទូលំទូលាយតាមរយៈការសិក្សាស្រាវជ្រាវ និងការអប់រំកម្រិតឧត្តមសិក្សា។

រាជរដ្ឋាភិបាលកម្ពុជាបានបរិច្ចាគដោយសុទ្ធចិត្តនូវទីតាំងមួយកន្លែងដើម្បីសាងសង់វិទ្យាស្ថានស្លឹករឹត ព្រមទាំងបានទទួលស្គាល់វិទ្យាស្ថានស្លឹករឹតជា "សកលវិទ្យាល័យ" ដើម្បីអនុញ្ញាតឲ្យវិទ្យាស្ថានស្លឹករឹតអាចបង្កើតជាគ្រឹះស្ថានលំដាប់សកលសម្រាប់ការសិក្សា និងការស្រាវជ្រាវជាន់ខ្ពស់។ នៅពេលដែលវិទ្យាស្ថានស្លឹករឹតចាប់ផ្តើមដំណើរការ វិទ្យាស្ថានស្លឹករឹតនឹងជ្រើសរើសនិស្សិតឈ្លាសវៃ និងសាស្ត្រាចារ្យល្បីៗ ព្រមទាំងអ្នកស្រាវជ្រាវដែលមានជំនាញផ្សេងៗគ្នាជុំវិញសកលលោកមកសិក្សាស្រាវជ្រាវ និងបង្រៀននៅវិទ្យាស្ថានស្លឹករឹត។

# សេចក្តីសង្ខេបអំពីជោគជ័យរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា

| អ្នកអាស្រ័យផល | ការពិពណ៌នាអំពីសារប្រយោជន៍ |
|---|---|
| សាលាបឋមសិក្សា និងអនុវិទ្យាល័យ | • ការរៀបចំ ការបោះផ្សាយ និងការចែកចាយសៀវភៅ «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)» ចំនួនមួយលានក្បាលជូនអនុវិទ្យាល័យជាង១៧០០ដែលភាគច្រើនស្ថិតនៅតំបន់ជនបទដាច់ស្រយាល<br>• ការរៀបចំ ការបោះផ្សាយ និងការចែកចាយសៀវភៅណែនាំសម្រាប់គ្រូបង្រៀន និងសៀវភៅលំហាត់ ព្រមជាមួយនឹងសៀវភៅសិក្សាសម្រាប់សិស្ស |
| សកលវិទ្យាល័យ | • ការណែនាំ និងការរៀបចំសិក្ខាសាលានៅតាមសាកលវិទ្យាល័យជាង២០០ នៅទូទាំងប្រទេសកម្ពុជា |
| ប៉ូលីស | • ការរៀបចំសិក្ខាសាលាសម្រាប់មន្ត្រីប៉ូលីសចំនួន៣០០នាក់ ស្តីអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ និងការទប់ស្កាត់ការកកើតឡើងជាថ្មីនៃឧក្រិដ្ឋកម្មទ្រង់ទ្រាយធំ |
| យោធា | • ការរៀបចំសិក្ខាសាលាសម្រាប់មន្ត្រីយោធា និងនាយទាហានចំនួន ៦៥០នាក់ ស្តីអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ការវិភាគលើការកកើតឡើង និងជោគជ័យរបស់មេដឹកនាំខ្មែរក្រហម ព្រមទាំងសិក្សាអំពីគោលនយោបាយ និងសកម្មភាពរបស់ខ្មែរក្រហម ដើម្បីយល់ដឹងអំពីមូលហេតុពិតប្រាកដ និងដើម្បីការទប់ស្កាត់ការកកើតឡើងជាថ្មីនៃឧក្រិដ្ឋកម្មទ្រង់ទ្រាយធំ |
| សហគមន៍ជនបទ | • ការរៀបចំវេទិកាអប់រំសាធារណៈតាមសហគមន៍នៅតំបន់ជនបទដាច់ស្រយាលនៃប្រទេសកម្ពុជាសម្រាប់ប្រជាជនពេញវ័យ |
| សហគមន៍ជនជាតិចាម | • ការអនុវត្តគម្រោងប្រវត្តិសាស្ត្រផ្ទាល់មាត់ជនជាតិចាម រួមមាន បទសម្ភាសន៍ ចំនួន ៤០០ ទាក់ទងនឹងដំណើរការនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា នៅក្នុងបរិបទនៃប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ |
| អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា<br>-- សាលាក្តីឧក្រិដ្ឋកម្មសង្គ្រាមអន្តរជាតិរបស់អង្គការសហប្រជាជាតិ | • ការផ្តល់ឲ្យអ្នកសអង្កេត ព្រះរាជអាជ្ញា ក្រុមមេធាវីការពារក្តី និងចៅក្រម របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា នូវឯកសារជាងរាប់សែនសន្លឹក សៀវភៅរាប់រយក្បាល ស៊ីឌី/ឌីវីឌីជាង១៣ន់ មីក្រូហ្វីម៥២៤ដុំ ឯកសារចម្លង និងបទសម្ភាសន៍រាប់សែនទំព័រ<br>• ការឆ្លើយតបនឹងសំណើសុំឯកសារគាំទ្រជាបន្តបន្ទាប់ឥតឈប់ឈរ ពីសំណាក់ព្រះរាជអាជ្ញា អ្នកស៊ើបអង្កេត ចៅក្រមសាលាដំបូង និងក្រុមមេធាវីការពារក្តី។ |



# វិទ្យាស្ថានស្លឹករឹត

## បូជនីយដ្ឋានសម្រាប់រំឭកដល់អតីតកាល និងគ្រឹះស្ថានសិក្សាសម្រាប់អនាគត

វិទ្យាស្ថានស្លឹករឹត គឺជាជំហានបន្ទាប់ និងជាការពង្រីកចក្ខុវិស័យរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា។ វិទ្យាស្ថានស្លឹករឹតនឹងដើរតួនាទីជាមជ្ឈមណ្ឌលអប់រំ មជ្ឈមណ្ឌលស្រាវជ្រាវ សារមន្ទីរនៃការចងចាំ ដែលនឹងផ្តល់ឲ្យអ្នកទស្សនានូវគោលគំនិតទូទៅទាក់ទងនឹងប្រវត្តិសាស្ត្រកម្ពុជាដើម្បីកសាងអនាគតរបស់កម្ពុជា។ បើទោះបីជារបបខ្មែរក្រហមបានសម្លាប់ប្រជាជនកម្ពុជាអស់ប្រមាណមួយភាគបី នៅក្នុងរយៈពេលបួនឆ្នាំយ៉ាងណាក៏ដោយ ក៏រាជរដ្ឋាភិបាលកម្ពុជាពុំទាន់បានបង្កើតនូវក្របខណ្ឌពេញលេញមួយសម្រាប់ដាក់បញ្ចូលឧក្រិដ្ឋកម្មឃោរឃៅទាំងអស់នេះ ទៅក្នុងបរិបទនៃកេរដំណែលវប្បធម៌ដ៏សម្បូរបែបរបស់កម្ពុជា ឬផ្តួចផ្តើមការផ្សះផ្សាជាតិឲ្យបានពេញលេញដែលជាជំនួយដល់ការធ្វើដំណើរទៅកាន់អនាគតដ៏ភ្លឺស្វាងមួយនៅឡើយទេ។

*បេសកកម្មរបស់វិទ្យាស្ថានស្លឹករឹត គឺពង្រឹងការយល់ដឹង និងផ្តល់ចំណេះដឹងអំពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការគោរពច្បាប់តាមរយៈការផ្តោតទៅលើកម្មវិធីសិក្សាអប់រំដែលប្រកបដោយជំនាញ និងមានលក្ខណៈជាសាធារណៈ ព្រមទាំងសេវាកម្ម កម្មវិធីសិក្សាស្រាវជ្រាវ កម្មវិធីយល់ដឹងទូទៅរបស់មនុស្សជាតិ និងកម្មវិធីតាមប្រព័ន្ធអ៊ីនធឺណេតសម្រាប់តំបន់ដាច់ស្រយាលឲ្យប្រើប្រាស់បណ្ណសារប្រវត្តិសាស្ត្រដ៏សម្បូរបែប និងមានប្រយោជន៍ រួមមាន ឯកសារ រូបថត និងសម្ភារសិក្សាដទៃទៀតជាច្រើន។*

# មជ្ឈមណ្ឌលសិក្សា និងស្រាវជ្រាវអន្តរជាតិ

វិទ្យាស្ថានស្លឹករឹត នឹងដើរតួនាទីជាវិទ្យាស្ថានផ្លូវការមួយដែលផ្តោតទៅលើការអប់រំអំពីឧក្រិដ្ឋកម្មឃោរឃៅ និងមជ្ឈមណ្ឌលស្រាវជ្រាវ ដែលប្រជាជនកម្ពុជាអាចចូលរួមជាមួយនឹងបញ្ញវន្តក្នុងតំបន់ និងអន្តរជាតិ ដើម្បីពង្រីកនូវការស្រាវជ្រាវរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាអំពីរបបខ្មែរក្រហម និងការវិភាគបែបសកលទៅលើហេតុការណ៍ដែលបានកើតឡើង ព្រមទាំងការសិក្សាទៅលើឫសគល់នៃឧក្រិដ្ឋកម្មឃោរឃៅ។ វិទ្យាស្ថានស្លឹករឹតមានបណ្ណសារដ្ឋានធំបង្គួរ ដែលតម្កល់ឯកសារដើមជាងមួយលានទំព័របន្សល់ទុកពីរបបខ្មែរក្រហម។ តាមរយៈបណ្ណសារនេះ អ្នកស្រាវជ្រាវនឹងអាចសិក្សាស្វែងយល់ ដោយអាចដាក់បញ្ចូលគំហើញទាំងនោះទៅក្នុងបរិបទទូលំទូលាយជាងមុនទាក់ទងនឹងប្រវត្តិសាស្ត្រ ស្ថាបត្យកម្ម និងវប្បធម៌របស់ខ្មែរ ព្រមទាំងអាចប្រើប្រាស់គំហើញទាំងនោះសម្រាប់បង្កើតជាមាគ៌ាមួយដែលឆ្ពោះទៅរកអនាគតចម្រុងចម្រើន។

វិទ្យាស្ថានស្លឹករឹត នឹងបង្កើតគ្រឹះស្ថានសិក្សាមួយដែលមានតួនាទីជាក់លាក់ដោយផ្តោតសំខាន់ទៅលើការទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅ និងការបំពានសិទ្ធិមនុស្ស តាមរយៈការបណ្តុះបណ្តាលអ្នកដឹកនាំវ័យក្មេងទាំងក្នុងវិស័យឯកជន និងរដ្ឋ ដោយផ្តល់នូវជំនាញផ្នែកវាយតម្លៃ និងវិភាគដែលចាំបាច់សម្រាប់តាមដានអំពីមូលហេតុ និងបរិយាកាសដែលអាចបង្កឲ្យមានឧក្រិដ្ឋកម្មឃោរឃៅកើតឡើង ព្រមទាំងពង្រឹងសមត្ថភាពរបស់អ្នកដឹកនាំវ័យក្មេងទាំងអស់នោះឲ្យចេះកសាង និងរក្សានូវបរិយាកាសនយោបាយ និងសង្គម ដោយឈរលើមូលដ្ឋានគ្រឹះនៃការគោរពច្បាប់ ការគ្រប់គ្រងជម្លោះដោយសន្តិវិធី និងការបង្កើតស្ថាប័នយុត្តិធម៌សម្រាប់សហគមន៍។



វិទ្យាស្ថានស្លឹករឹត នឹងជ្រើសរើសនិសិត្សកម្ពុជា និសិត្សក្នុងតំបន់ និងអន្តរជាតិដែលមានទេពកោសល្យ ដោយមានការចូលរួមពីសំណាក់អ្នកស្រាវជ្រាវ បញ្ញវន្តក្នុងស្រុក និងក្រៅស្រុក ដើម្បីបង្កើតនូវបរិយាកាសសិក្សាមួយដែលរីករាយ និងប្រកួតប្រជែង។

## ការលើកកម្ពស់យុត្តិធម៌ សិទ្ធិមនុស្ស និងនីតិរដ្ឋនៅតំបន់អាស៊ីអាគ្នេយ៍ និងតំបន់ដទៃទៀត

មជ្ឈមណ្ឌលឯកសារកម្ពុជាបានអនុវត្តជាគំរូក្នុងការចងក្រងឯកសារឧក្រិដ្ឋកម្មឃោរឃៅ ដោយជំរុញឲ្យតុលាការអន្តរជាតិទទួលជោគជ័យក្នុងការកាត់ទោសមេដឹកនាំជាន់ខ្ពស់នៃរបបខ្មែរក្រហម ដែលប៉ុនប៉ងបំផ្លាញចំណេះដឹង និងការយល់ដឹងរបស់មនុស្សជំនាន់ក្រោយ។ ការងាររបស់វិទ្យាស្ថានស្លឹករឹត នឹងរួមបញ្ចូលនូវការកែតម្រូវគំរូមិនល្អទាំងនោះ ដើម្បីអនុវត្តឲ្យមានប្រសិទ្ធភាព និងជោគជ័យនៅក្នុងបរិបទដទៃ ដែលឈានទៅដល់ការទប់ស្កាត់ជនទាំងឡាយណាដែលមានបំណងបង្កវិនាសសកម្មដល់ហេដ្ឋារចនាសម្ព័ន្ធ និងគ្រឹះស្ថានសង្គមនៅក្នុងប្រទេសកម្ពុជា និងពិភពលោក។ ចក្ខុវិស័យ និងបេសកកម្មរបស់វិទ្យាស្ថានស្លឹករឹត មានភាពចាំបាច់ដែលអាចប្រើប្រាស់ដើម្បីធ្វើអន្តរាគមន៍ដោយជោគជ័យក្នុងការទប់ស្កាត់រាល់គោលបំណងបង្កភាពអន្តរាយដល់មនុស្សជាតិនាពេលអនាគត។

# វិទ្យាស្ថានស្លឹករឹត

## បូជនីយដ្ឋាននៃការចងចាំដ៏រស់រវើក និងមជ្ឈមណ្ឌលអប់រំ

ទីតាំងដែលបង្កើតឡើងដោយគំនិតច្នៃប្រឌិត ស្ថាបត្យកម្ម និងសោភ័ណភាព នឹងជះឥទ្ធពលដល់ការគិតពិចារណា ការប្រាស្រ័យទាក់ទង និងការឲ្យតម្លៃទៅលើស្ថាប័នរបស់បុគ្គលដែលតំណាងឲ្យស្ថាប័ននោះ។ ទីតាំងមួយដែលរចនាឡើងដោយការផ្ចិតផ្ចង់អាចទាក់ទាញ បង្កើនថាមពល និងលើកទឹកចិត្តមនុស្ស ព្រមទាំងអាចលើកកម្ពស់ដល់ភាពរីកចម្រើន។ កត្តាទាំងអស់នេះហើយដែលមានតួនាទីចម្បងក្នុងការបកស្រាយបេសកកម្មរបស់វិទ្យាស្ថានស្លឹករឹតឲ្យលេចចេញជារូបរាងជាក់ស្តែង។ ស្ថាបនិករបស់វិទ្យាស្ថានស្លឹករឹតបានប្តេជ្ញាថាអគារនេះត្រូវតែប្រសើរជាងរូបរាង សមាសធាតុ និងភាពទុទ្ទិដ្ឋិនិយមនៃស្ថាបត្យកម្មដែលឧទ្ទិសដល់ការចងចាំរបស់អ្នករស់រានមានជីវិតដែលធ្លាប់បានកសាងកន្លងមក។ មិនតែប៉ុណ្ណោះ ភាពខុសប្លែកនេះបានបំបែកចេញនូវការយល់ឃើញបែបចាស់គំរិលដែលការរចនាកន្លងមកភាគច្រើនធ្វើឡើងដោយបុរស ដើម្បីទទួលស្គាល់ជាប្រវត្តិសាស្ត្រអំពីឧក្រិដ្ឋកម្មឃោរឃៅដែលបានបង្កនូវផលប៉ះពាល់ជាហិង្សាទៅលើស្ត្រី និងកុមារ។



*ដើម្បីសម្រេចបានគោលដៅខាងលើនេះ វិទ្យាស្ថានស្លឹករឹតបានធ្វើការជាមួយស្ថាបត្យករកម្រិតសកលលោក គឺ អ្នកស្រី ហ្សាហា ហាឌីត នៃទីក្រុងឡុងដ៍ ឲ្យចូលរួមរចនាអាគារវិទ្យាស្ថានស្លឹករឹតដ៏ថ្មីសន្លាងមួយ។ ស្ថាបត្យកម្មរបស់អ្នកស្រី ហ្សាហា ហាឌីត ដែលមានសញ្ជាតិដើមជាជនជាតិអ៊ីរ៉ាក់ និងជាស្ថាបត្យករស្ត្រីតែម្នាក់គត់ ដែលទទួលបានពានរង្វាន់ព្រីត្សខឺ ក្នុងវិស័យស្ថាបត្យកម្ម មានលក្ខណៈគួរឲ្យកត់សម្គាល់ចំពោះការច្នៃប្រឌិត និងការបង្កើតថ្មី។*



*ចក្ខុវិស័យរបស់លោក ឆាំង យុ មានលក្ខណៈទំនើបកម្ម និងច្នៃប្រឌិតថ្មី។ យើងសង្ឃឹមថានឹងធ្វើឲ្យទស្សនវិស័យរបស់លោកក្លាយជាការពិតតាមរយៈការរចនាអគារទំនើបមួយដែលចងចាំនូវកេរដំណែលនោះហើយមិនត្រឹមតែប៉ុណ្ណោះសោតក៏ឆ្លុះបញ្ចាំងអំពីជំនឿដ៏មុតមាំ និងភាពសុទិដ្ឋិនិយមសម្រាប់អនាគត ដោយប្រើប្រាស់ការអប់រំ ការយល់ដឹង និងគំនិតបង្កើតថ្មី ដើម្បីឲ្យអ្នកទស្សនាអាចចូលរួមដោយវិជ្ជមាន។”*

ហ្សាហា ហាឌីត

*យើងមានវិញ្ញាសារសំខាន់ពីរ៖*
*ទីមួយ យើងប្រឈមមុខនឹងតម្រូវការដ៏ខ្ពស់របស់លោក ឆាំង យុ។ ទីពីរ យើងនឹងសម្រេចឲ្យបាននូវអ្វីដែលលើសពីការរំពឹងទុករបស់ លោក ឆាំង យុ។”*

ហ្សាហា ហាឌីត



“

*បូជនីយដ្ឋាននៃការចងចាំដែលល្អបំផុត មិនមែនជាទីតាំងដែលយើងទស្សនាម្តងរួចហើយដើរចេញនោះទេ។ បូជនីយដ្ឋាននៃការចងចាំដែលល្អបំផុត គឺជំរុញឲ្យមានការត្រិះរិះពិចារណា និងការរំឭក ព្រមទាំងជាទីកន្លែងសាធារណៈដ៏រស់រវើក និងពោរពេញដោយថាមពលដែលអាចបំផុសឲ្យមានការចូលរួមពីសំណាក់មនុស្សគ្រប់ជំនាន់នៅក្នុងសហគមន៍។*

*វិទ្យាស្ថានស្លឹករឹត នឹងមិនត្រឹមតែផ្តោតទៅលើអតីតកាលតែប៉ុណ្ណោះនោះទេប៉ុន្តែតែថែមទាំងប៉ុនប៉ងបង្កើតនូវវិទ្យាស្ថានមួយដែលធ្វើការបំភ្លឺ ជាទីតាំងដែលមនុស្សជំនាន់ថ្មីអាចសិក្សាអំពីមេរៀនសោកនាដកម្មកាលពីអតីតកាល ទន្ទឹមនឹងស្វែងរកនូវវិធីសាស្ត្រ ដើម្បីព្យាបាលរបួសអតីតកាល និងបន្តទៅមុខ។ ការតាំងចិត្ត ការប្តេជ្ញា និងជំនឿចំពោះអនាគតរបស់យើង គឺជាអ្វីដែលឆ្លុះបញ្ចាំងអំពីយើង។”*

ឆាំង យុ

ឆាំង យុ ជានាយកប្រតិបត្តិនៃមជ្ឈមណ្ឌលឯកសារកម្ពុជា និងជាស្ថាបនិកនៃវិទ្យាស្ថានស្លឹករឹត។ លោក ជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។ នៅពេលដែលលោកមានអាយុ១៥ឆ្នាំ លោកត្រូវបានកងឈ្លបខ្មែរក្រហមចាប់ខ្លួន ធ្វើទារុណ្ណកម្ម និងឃុំឃាំង ដោយពុំមានសវនាការ ដោយសារតែលោកបានលួចបេះផ្សិតមកឲ្យបងស្រីដែលកំពុងមានផ្ទៃពោះ។ បន្ទាប់មក លោកបានរត់គេចខ្លួនទៅដល់សហរដ្ឋអាម៉េរិកក្នុងនាមជាជនភៀសខ្លួន។ ក្រោយមក លោកចាប់ផ្តើមដឹកនាំកិច្ចខិតខំប្រឹងប្រែងយូរអង្វែងក្នុងការលើកកម្ពស់ការចងចាំ និងយុត្តិធម៌នៅក្នុងប្រទេសកម្ពុជា។ លោកបានវិលត្រឡប់មកប្រទេសកម្ពុជាវិញនៅក្នុងទសវត្សរ៍ឆ្នាំ១៩៩០ ដើម្បីគ្រប់គ្រងកម្មវិធីបណ្តុះបណ្តាលសិទ្ធិមនុស្ស និងលទ្ធិប្រជាធិបតេយ្យ ព្រមទាំងក្លាយជាអ្នកដឹកនាំមជ្ឈមណ្ឌលឯកសារកម្ពុជានៅក្នុងឆ្នាំ១៩៩៥ នៅពេលដែលមជ្ឈមណ្ឌលនេះត្រូវបានបង្កើតឡើងក្នុងនាមជាការិយាល័យស៊ើបអង្កេតនៃកម្មវិធីស្រាវជ្រាវអំពើប្រល័យពូជសាសន៍នៅកម្ពុជា របស់សាកលវិទ្យាល័យយ៉េល។

លោកបានបន្តកិច្ចប្រតិបត្តិការមជ្ឈមណ្ឌលនេះ បន្ទាប់ពីមជ្ឈមណ្ឌលឯកសារកម្ពុជាបានក្លាយទៅជាអង្គការក្រៅរដ្ឋាភិបាលឯករាជ្យមួយនៅក្នុងឆ្នាំ១៩៩៧។ នៅក្នុងឆ្នាំ២០០០ លោកទទួលបានពានរង្វាន់សេរីភាពរបស់ប្រធានាធិបតីសហរដ្ឋអាម៉េរិក ទ្រូម៉េន និងរីហ្គេន ពីមូលនិធិនៃការចងចាំរបស់ជនរងគ្រោះនៃលទ្ធិកុម្មុយនីស្ត នៅរដ្ឋវ៉ាស៊ីងតោន។ លោកត្រូវបានរាយនាមជា «វីរបុរសអាស៊ីទាំង៦០» របស់ទស្សនាវដ្តី ថាម នៅក្នុងឆ្នាំ ២០០៦ និងជាបុគ្គលមួយរូបក្នុង «ទស្សនាវដ្តីថាម ១០០» ដែលមានឥទ្ធិពលបំផុតក្នុងពិភពលោក នៅក្នុងឆ្នាំ២០០៧ សម្រាប់ជំហររបស់លោកក្នុងការប្រឆាំងនិទណ្ឌភាពនៅក្នុងប្រទេសកម្ពុជា និងប្រទេសដទៃទៀត។ បច្ចុប្បន្ន លោកកំពុងដឹកនាំកិច្ចខិតខំប្រឹងប្រែងរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាក្នុងការបង្កើតវិទ្យាស្ថានស្លឹករឹត ដែលជាមជ្ឈមណ្ឌលអចិន្ត្រៃយ៍សម្រាប់ការសិក្សាអំពីអំពើប្រល័យពូជសាសន៍នៅក្នុងតំបន់អាស៊ីដែលមានទីតាំងនៅទីក្រុងភ្នំពេញ។

វិទ្យាស្ថានស្លឹករឹត នឹងបន្តផ្តល់តម្លៃដល់ការចងចាំរបស់ជនរងគ្រោះពីរបបខ្មែរក្រហមនៅក្នុងបរិបទ និងក្របខណ្ឌដ៏ទូលាយរបស់ប្រវត្តិសាស្ត្រកម្ពុជា តាមរយៈការរំលេចឡើងនូវកេរដំណែលវប្បធម៌ ស្មារតី និងសិល្បៈ។ វិទ្យាស្ថានស្លឹករឹតនឹងផ្តោតចម្បងលើការចងចាំ ការយល់ដឹង និងការព្យាបាលរបួសពីអតីតកាល បច្ចុប្បន្នកាល និងអនាគតកាលរបស់កម្ពុជា។ ទេសចរដែលមកដល់សារមន្ទីរនៃការចងចាំនឹងបានស្វែងយល់អំពីការចូលរួមផ្នែកស្មារតី ក្តីសង្ឃឹម ការផ្សះផ្សា និងការជាសះស្បើយពីរបួសអតីតកាល។ អគារនេះត្រូវបានរចនាឡើងដោយស្ថាបត្យករ និងវិស្វករដែលទទួលបានការគោរពពីមជ្ឈដ្ឋានទូទៅក្នុងពិភពលោក ដោយយកចិត្តទុកដាក់ខ្ពស់ទៅលើស្ថេរភាព សុវត្ថិភាព និងធានាថាមានការប៉ះពាល់ទៅលើបរិស្ថានដ៏តិចតួចបំផុត។

ក្រុមស្ថាបត្យកររបស់អ្នកស្រី ហ្សាហា ហាឌីត បានបញ្ចប់ការរចនាអគារ និងបានចាប់ផ្តើមនូវដំហានបន្តបន្ទាប់ទៀត រួមមានការរចនាប្លង់លម្អិត ការអភិវឌ្ឍការរចនា និងដំណើរការដេញថ្លៃ។ គោលដៅនៃដំហានបន្ទាប់តម្រូវឲ្យមានការដាក់បញ្ចូលទៅក្នុងការរចនានូវសមាសធាតុផ្សំផ្នែកបច្ចេកទេសសំខាន់ៗដែលចាំបាច់សម្រាប់បណ្តុំអគារ ដើម្បីជានាយ៉ាងប្រាកដថាអាចរក្សាបាននូវនិរន្តរភាពមួយរបស់អគារដែលនឹងនៅគង់វង្សរហូតដល់ទៅ១សតវត្សរ៍ ជាមួយនឹងការកែលម្អតិចតួច និងប្រើប្រាស់ថាមពលតិចបំផុតតាមរយៈការប្រើប្រាស់ថាមពលពីពន្លឺព្រះអាទិត្យ។





អគារបៃតងនេះ នឹងប្រើប្រាស់បច្ចេកវិទ្យា និងប្រព័ន្ធគ្រប់គ្រងដែលប្រកបដោយប្រសិទ្ធភាព ដើម្បីកាត់បន្ថយការបញ្ចេញកាកសំណល់ព្រមទាំងប្រើប្រាស់ប្រភពថាមពលកើតឡើងវិញ ដើម្បីកាត់បន្ថយការបំភាយឧស្ម័នកាបូនឲ្យនៅតិចបំផុត ក្នុងគោលបំណងធ្វើជាគំរូក្នុងការបំផុសនូវការយល់ដឹងអំពីបរិស្ថានរបស់កម្ពុជាលើវិស័យស្ថាបត្យកម្ម វិស្វកម្ម និងសំណង់។
ដោយសារតែការរចនា និងវិស្វកម្មនៃបណ្តុំអគារនេះមានភាពស្មុគស្មាញ និងពោរពេញដោយឧបសគ្គ ដូច្នេះយើងបានជ្រើសរើសយកក្រុមវិស្វកម្មឈ្មោះ«អារុប»ដែលជាក្រុមហ៊ុនវិស្វកម្មសំណង់ដ៏ល្បីមួយនៅលើពិភពលោក ឲ្យធ្វើការសាងសង់អគារនេះ។



# សេចក្ដីសង្ខេបពីកម្មវិធីរបស់វិទ្យាស្ថានស្លឹករឹត

- ផ្ដល់ការប្រឹក្សា និងជំនួយបច្ចេកទេសក្នុងការបង្កើត និងថែរក្សាបណ្ណសារដ្ឋានថ្មីអំពីឧក្រិដ្ឋថ្មីដែលអាចកើតឡើង។

- ពង្រីកនូវគំនិតផ្ដួចផ្ដើមជាសកលរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដើម្បីជាជំនួយដល់ការបង្កើតនូវស្ថាបនិក និងមជ្ឈមណ្ឌលឯកសារ និងអប់រំទាក់ទងនឹងឧក្រិដ្ឋកម្មឃោរឃៅដែលប្រហាក់ប្រហែលនៅតំបន់ផ្សេងទៀត។ លោក ឆាំង យុ នាយកវិទ្យាស្ថានស្លឹករឹតបាន ដើរតួនាទីជាអ្នកផ្ដល់ប្រឹក្សាយោបល់ជាន់ខ្ពស់ដល់រដ្ឋាភិបាលនៃប្រទេសជាច្រើន។ មិនតែប៉ុណ្ណោះ លោកក៏ជាសមាជិកនៃក្រុមប្រឹក្សាភិបាលជាន់ខ្ពស់នៃក្រុមពិនិត្យ និងចងក្រងឯកសារទាក់ទងនឹងឧក្រិដ្ឋកម្មឃោរឃៅ ដែលបង្កើតឡើងសម្រាប់ប្រទេសស៊ីរី និងភូមា។

- ពង្រីកនូវភាពជោគជ័យរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ក្នុងការបង្កើតនូវកម្មវិធីសិក្សាអប់រំ និងវគ្គបណ្ដុះបណ្ដាលគ្រូបង្រៀនផ្នែកប្រវត្តិសាស្ត្រ អក្សរសាស្ត្រ និងសីលធម៌ ចែកជូនសៀវភៅសិក្សា និងសម្ភារផ្សេងៗ ព្រមទាំងទម្រង់បែបបទដល់សាលាក្នុងតំបន់ សាកលវិទ្យាល័យ និងក្រុមសហគមន៍នានាទូទាំងប្រទេសកម្ពុជា ណែនាំសិស្ស និងអប់រំមនុស្សពេញវ័យអំពីប្រវត្តិសាស្ត្រនៃឧក្រិដ្ឋកម្មឃោរឃៅ ដើម្បីអភិរក្ស និងរក្សាទុកនូវការចងចាំអំពីរឿងរ៉ាវទាំងនោះ និងបណ្ដុះនូវការតស៊ូប្រឆាំងនឹងការកើតឡើងវិញនូវអំពើឃោរឃៅ។

- បន្តរៀបចំធនធានបណ្ណសារដ៏ធំរបស់ខ្លួន ដើម្បីផ្ដល់នូវភ័ស្តុតាងឯកសារដល់អ្នកស៊ើបអង្កេត ចៅក្រម ព្រះរាជអាជ្ញា និងមេធាវីការពារក្ដីនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។ បញ្ញវន្ត ចៅក្រម មេធាវី និងអង្គការសិទ្ធិមនុស្សទូទាំងសកលលោកបានទទួលស្គាល់ថា បើពុំមានការផ្ដល់ឲ្យ និងជំនួយជាបណ្ណសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជាទេនោះ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានឹងត្រូវប្រឈមនឹងឧបសគ្គក្នុងការសម្រេចបាននូវការស៊ើបអង្កេតទាក់ទងនឹងការកាត់ទោសមុខសញ្ញារបស់ខ្លួន។ មជ្ឈមណ្ឌលឯកសារកម្ពុជាបានជួយសន្សំសំចៃទឹកប្រាក់រាប់លានដុល្លារអាមេរិកដល់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដោយរៀបចំឯកសារភ័ស្តុតាងទាំងនេះឲ្យមានរួចមុនជាស្រេច និងអាចប្រើប្រាស់បានជាផ្លូវការ។

- បន្តកម្មវិធីរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាដែលបានជួយអ្នករស់រានមានជីវិតពីអំពើប្រល័យពូជសាសន៍រាប់ពាន់នាក់ដាក់ពាក្យសុំជាដើមបណ្ដឹងរដ្ឋប្បវេណីនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីដាក់ពាក្យបណ្ដឹងតាមផ្លូវច្បាប់អំពីការបំផ្លាញ ព្រមទាំងជួយសម្រួលដល់ការធ្វើដំណើរពីតំបន់ដាច់ស្រយាលមកធ្វើការអង្កេត និងចូលរួមនៅក្នុងដំណើរការសវនាការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។

- ពង្រីកកម្មវិធីស្រាវជ្រាវលើលក្ខខណ្ឌសង្គម វប្បធម៌ និងនយោបាយក្នុងរបបប្រល័យពូជសាសន៍ខ្មែរក្រហមដែលជាលទ្ធផលនៃឧក្រិដ្ឋម្មឃោរឃៅ។ របាយការណ៍នាពេលថ្មីៗនេះបានបង្ហាញយ៉ាងលម្អិតថាជនជាតិដើមភាគតិចចាមត្រូវបានក្លាយជាគោលដៅ និងរងឥទ្ធិពលពីសំណាក់មេដឹកនាំខ្មែរក្រហម។

- បណ្ដុះបណ្ដាលយោធា និងមន្ត្រីប៉ូលីស លើវិធីសាស្ត្រធ្វើការស៊ើបអង្កេតទៅលើរណ្ដៅសាកសព កត់ត្រាសក្ខីភាពរបស់សាក្សី និងធានាការការពារដល់សាក្សី និងជនជាប់ចោទ។

- ធ្វើអង្កេតថ្នាក់ជាតិទៅលើទីតាំងវប្បធម៌ នយោបាយ និងស្ថានភាពនៃទីតាំងទាំងនោះ។ ការអង្កេតថ្មីមួយបានធ្វើទៅលើវិហារអ៊ីស្លាមចំនួន៣៩៤ នៅក្នុងប្រទេសកម្ពុជាដោយចងក្រងជាឯកសាអំពីទីតាំង និងលក្ខខណ្ឌនៃអគារទាំងនោះ។

- ផ្ដល់នូវការព្យាបាលផ្នែកសុខភាពផ្លូវចិត្តដល់អ្នករស់រានមានជីវិតពីអំពើទារុណ្ណកម្ម និងការបំពានផ្នែកស្មារតី។

## សេចក្តីសង្ខេបពីកម្មវិធីរបស់វិទ្យាស្ថានស្លឹករឹត (បន្ត)

- ផ្តល់ឲ្យទេសចរនូវគោលគំនិតទូលំទូលាយទាក់ទងនឹងការព្យាបាលរបួសពីអតីតកាល និងការផ្សះផ្សា តាមរយៈពិព័រណ៌បទបង្ហាញ និងកម្មវិធីអប់រំ។ លើកកម្ពស់ការជាសះស្បើយថ្នាក់ជាតិដោយផ្តោតលើការអប់រំ និងការយល់ដឹងរបស់មនុស្សគ្រប់វ័យ។ រៀបចំពិធីបែបសាសនា និងវប្បធម៌ ដើម្បីជាជំនួយដល់ការស្តារឡើងវិញ និងពង្រឹងកេរដំណែលវប្បធម៌ និងអត្តសញ្ញាណជាតិ ព្រមទាំងពង្រីកដល់សហគមន៍ពិភពលោក។

- បង្កើននូវបទពិសោធន៍ផ្នែកវប្បធម៌ និងប្រវត្តិសាស្ត្រដល់ទេសចរនៅក្នុងប្រទេសកម្ពុជា ព្រមទាំងផ្តល់វិភាគទានដល់ការស្វែងយល់ និងការយល់ដឹងជាសាធារណៈតាមរយៈសារមន្ទីរនៃការចងចាំ។

- ផ្តល់ផលប្រយោជន៍ និងលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជនកម្ពុជា ដែល៥០ភាគរយស្ថិតនៅបន្ទាត់នៃភាពក្រីក្រតាមរយៈការផ្តល់ឱកាសការងារ ការបណ្តុះបណ្តាលលើជំនាញដែលចាំបាច់ដើម្បីរក្សានូវអាជីពនៅក្នុងវិស័យទេសចរណ៍ និងពង្រីកការគាំពារសេវាកម្មទេសចរណ៍នៅក្នុងតំបន់ ដូចជា មធ្យោបាយធ្វើដំណើរ មគ្គុទ្ទេសក៍ ផ្ទះសំណាក់ និងភោជនីយដ្ឋាន។

# ការសាងសង់វិទ្យាស្ថានស្លឹករឹត និងការឧបត្ថម្ភថវិកា

តម្លៃប៉ាន់ស្មានសម្រាប់ការរចនា និងសាងសង់វិទ្យាស្ថានគឺប្រមាណជាង ៥០លានដុល្លារសហរដ្ឋអាម៉េរិក។ វិទ្យាស្ថានស្លឹករឹតបានផ្តួចផ្តើមនូវយុទ្ធនាការទ្រទ្រង់ទ្រាយធំជាសកល ដើម្បីរៃអង្គាសមូលនិធិចាំបាច់សម្រាប់ទ្រទ្រង់លើចំណាយទាំងអស់។ នាពេលប៉ុន្មានឆ្នាំកន្លងមក មជ្ឈមណ្ឌលឯកសារកម្ពុជាទទួលបានការគាំទ្រពីសំណាក់រាជរដ្ឋាភិបាល មូលនិធិ ក្រុមហ៊ុនឯកជន និងបុគ្គល។ មិនតែប៉ុណ្ណោះ រាជរដ្ឋាភិបាលកម្ពុជាបានផ្តល់ឲ្យមជ្ឈមណ្ឌលឯកសារកម្ពុជានូវសិទ្ធិក្នុងការកាន់កាប់ដីធំមួយកន្លែងនៅកណ្តាលរាជធានីភ្នំពេញ ដែលវិទ្យាស្ថានស្លឹករឹតនឹងត្រូវបានសាងសង់ឡើងនៅជាប់នឹងសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។ យុទ្ធនាការទ្រទ្រង់ទ្រាយធំនេះ គឺជាការប៉ុនប៉ងដ៏មុតមាំ និងធំធេងរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ស្របពេលដែលស្ថាប័ននេះកំពុងរៀបចំខ្លួនទៅជាវិទ្យាស្ថានស្លឹករឹត។ ជោគជ័យនឹងផ្អែកលើការគាំទ្រ និងការប្តេជ្ញាដោយសុទ្ធចិត្តពីម្ចាស់ជំនួយអន្តរជាតិ ទាំងអ្នកដែលធ្លាប់គាំទ្រកន្លងមក និងអ្នកដែលទើបនឹងចាប់ផ្តើមស្គាល់មជ្ឈមណ្ឌលឯកសារកម្ពុជា។ ទំហំអំណោយ និងការដាក់ឈ្មោះម្ចាស់អំណោយត្រូវបានដាក់បញ្ចូលនៅក្នុងឯកសារសម្រាប់រៃអង្គាសនេះ។

ឯកសារនេះផ្តល់នូវការណែនាំមួយអំពីកម្រិតនៃការគាំទ្រដែលចាំបាច់សម្រាប់ភាពជោគជ័យ។ បន្ថែមពីលើការគាំទ្រសាងសង់អគាររបស់វិទ្យាស្ថាននេះ យុទ្ធនាការនេះក៏រៀបចំឡើងដើម្បីផ្តោតលើការប្តេជ្ញាចិត្តគាំទ្រដល់ការចំណាយប្រតិបត្តិការប្រចាំឆ្នាំ និងការផ្តល់នូវទាយជ្ជទាន ដើម្បីធ្វើការទូទាត់លើចំណាយអស់ទាំង។ យោងតាមការប៉ាន់ស្មាននាពេលបច្ចុប្បន្នគម្រោងថវិកាប្រតិបត្តិការដែលគ្រោងទុករយៈពេលប្រាំឆ្នាំសម្រាប់វិទ្យាស្ថានស្លឹករឹតមានចំនួន៩,៨លានដុល្លារអាម៉េរិក ឬប្រហែល ១,៥លានក្នុងមួយឆ្នាំ អមជាមួយនឹងចំណាយបន្ថែម ១,៨លានដុល្លារអាម៉េរិក ក្នុងឆ្នាំ២០១៨ សម្រាប់ការចំណាយលើសម្ភារបរិក្ខាផ្សេងៗ។ ដោយផ្នែកខ្លះនៃថវិកាអស់ទាំងនេះទទួលបានមកពីប្រាក់សន្សំ និងប្រភពមិនមែនជំនួយដទៃទៀត ក៏ប៉ុន្តែការគាំទ្រសប្បុរសដោយសុទ្ធចិត្តនៅតែចាំបាច់សម្រាប់ថ្ងៃខាងមុខ។

*យើងសង្ឃឹមថាអ្នកដែលអានឯកសារអែង្គាសនេះនឹងពិចារណាក្នុងការចូលរួមវិភាគទានសប្បុរស និងផ្សព្វផ្សាយជាសកលដល់អ្នកដទៃទៀតដែលផ្តល់តម្លៃដល់ការងាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា។*

# ការទទួលស្គាល់អ្នកឧបត្ថម្ភ

វិទ្យាស្ថានស្លឹករឹតសម្តែងនូវសេចក្តីដឹងគុណចំពោះសប្បុរសជនទាំងឡាយណាដែលគាំទ្រកិច្ចខិតខំប្រឹងប្រែងនៃយុទ្ធនាការអែង្គាស ព្រមទាំងទទួលស្គាល់អ្នកទាំងនោះដូចខាងក្រោម៖

- អ្នកឧបត្ថម្ភទឹកប្រាក់ចំនួន ៧៥០,០០០ ដុល្លារសហរដ្ឋអាម៉េរិក ឬច្រើនជាងនេះនឹងទទួលបានឱកាសដាក់ឈ្មោះផ្ទាល់លើផ្នែកសំខាន់របស់អគារ (សូមមើលបញ្ជីដែលភ្ជាប់មកជាមួយ)។
- អ្នកឧបត្ថម្ភទាំងអស់ដែលបរិច្ចាគទឹកប្រាក់ចំនួន ២៥,០០០ ដុល្លារសហរដ្ឋអាម៉េរិក ឬច្រើនជាងនេះនឹងទទួលបានការចារឈ្មោះនៅលើជញ្ជាំងដែលស្ថិតនៅក្នុងអគារចម្បងរបស់វិទ្យាស្ថានស្លឹករឹត។
- អ្នកឧបត្ថម្ភទាំងអស់ដែលផ្តល់វិភាគទានដល់យុទ្ធនាការនេះក្នុងទំហំណាមួយក៏ដោយ នឹងត្រូវបានបោះពុម្ពផ្សាយនៅក្នុងសៀវភៅ និងនៅលើគេហទំព័ររបស់វិទ្យាស្ថានស្លឹករឹត។



# អនាគតដែលប្រកបដោយមនុស្សធម៌ និងយុត្តិធម៌

នៅពេលដែលសាងសង់រួចរាល់ វិទ្យាស្ថានស្លឹករឹតនឹងបម្រើប្រយោជន៍សាធារណជនទូទៅយ៉ាងទូលំទូលាយ។ លើសពីតួនាទីគាំពារផ្នែកអប់រំ ស្រាវជ្រាវ និងវប្បធម៌របស់ខ្លួន វិទ្យាស្ថានស្លឹករឹតនឹងចូលរួមចំណែកក្នុងសេដ្ឋកិច្ចកម្ពុជាតាមរយៈការបង្កើតការងារ និងសមត្ថភាពក្នុងការទាក់ទាញ មិនត្រឹមតែប្រជាជនកម្ពុជាតែប៉ុណ្ណោះទេ ប៉ុន្តែថែមទាំង សិស្សានុសិស្សបញ្ញវន្ត អ្នកស្រាវជ្រាវ ព្រមទាំងទេសចរដែលយល់ដឹង និងប្ដេជ្ញាចំពោះសង្គមពីជុំវិញពិភពលោកទៀតផង។ តាមរយៈកម្មវិធីរបស់ខ្លួន វិទ្យាស្ថានស្លឹករឹតក៏ជំរុញនូវចំណាប់អារម្មណ៍ និងការចូលរួមរបស់យុវជនកម្ពុជា នៅក្នុងប្រវត្តិសាស្ត្ររបស់ប្រទេសខ្លួន និងការប្ដេជ្ញាក្នុងការបង្កើតនូវស្ថាប័នប្រជាធិបតេយ្យមួយ។ កម្មវិធីអប់រំដោយចុះផ្ទាល់ទៅតាមសហគមន៍មូលដ្ឋានរបស់វិទ្យាស្ថានស្លឹករឹត នឹងផ្ដល់ឲ្យនូវបរិក្ខា និងកម្មវិធីសិក្សា ដើម្បីធ្វើឲ្យវិស័យអប់រំសាធារណៈកម្រិតបឋមសិក្សាវិទ្យាល័យ និងសាកលវិទ្យាល័យមានភាពរីកចម្រើន។

កម្ពុជាជាប្រទេសក្រីក្រមួយក្នុងចំណោមប្រទេសក្នុងតំបន់អាស៊ី។ ស្ទើរតែ៥០ភាគរយនៃចំណូលរបស់រាជរដ្ឋាភិបាលកម្ពុជាបានមកពីការឧបត្ថម្ភរបស់សហគមន៍អន្តរជាតិ។ ឈរលើគោលជំហររិជ្ជមាន សេដ្ឋកិច្ចកម្ពុជាកំពុងមានកំណើនជាបន្តបន្ទាប់។ ប្រជាជនជាង៥០ភាគរយស្ថិតក្នុងក្រុមអាយុក្រោម២៥ឆ្នាំ បានសបញ្ជាក់អំពីសក្ដានុពលដ៏វិសេសវិសាលមួយ។ យើងរំពឹងថា គុណប្រយោជន៍ដល់សេដ្ឋកិច្ចពីវិទ្យាស្ថានស្លឹករឹត នឹងធ្វើឲ្យមានការរីកចម្រើនដល់ស្ថានភាពសេដ្ឋកិច្ចរបស់អ្នកដែលក្រោមបន្ទាត់ភាពក្រីក្រ និងមធ្យម តាមរយៈការបង្កើតការងារដោយផ្ទាល់ និងប្រយោល។


R'kids
Five
:Second



អាសយដ្ឋាននៅកម្ពុជា
មជ្ឈមណ្ឌលឯកសារកម្ពុជា/ វិទ្យាស្ថានស្លឹករឹត
ផ្ទះលេខ ៦៦, មហាវិថី ព្រះសីហនុ
ប្រអប់សំបុត្រលេខ ១១១០
រាជធានីភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា
ទូរសព្ទ៖ (៨៥៥) ២៣ ២១១ ៨៧៥

បុគ្គលសម្រាប់ទំនាក់ទំនងនៅកម្ពុជា
ឆាំង យុ
(៨៥៥) ១២ ៩០៥ ៥៩៥
(៨៥៥) ១២ ៣៣៣ ៩៦៨
Dccam@online.com.kh

ជី ទេរិទ្ធិ
(៨៥៥) ២៣ ២១១ ៨៧៥
(៨៥៥) ២៣ ២១០ ៣៥៨
truthterith.c@dccam.org

អាសយដ្ឋាននៅសហរដ្ឋអាម៉េរិក
មជ្ឈមណ្ឌលឯកសារកម្ពុជា/ វិទ្យាស្ថានស្លឹករឹត
Hill Hall, Room 141,
360 Martin Luther King Jr. Blvd.,
Newark, NJ 07102
USA

បុគ្គលសម្រាប់ទំនាក់ទំនងនៅសហរដ្ឋអាម៉េរិក
Markus Zimmer
(១)-៨០១-៧៣៣-៦២៨២
zimmermb@gmail.com

John Ciorciari
(១)-២០២-៤៣១-៥០៩០
ciorciari@gmail.com

(៨៥៥) ១២ ៣៣៣ ៩៦៨ | dccam@online.com.kh | www.cambodiasri.org

រូបភាព៖ MIR   រូបថត៖ អ៊ូច មករា ឧបត្ថម្ភការបោះពុម្ពដោយ ធនាគារ អេស៊ីលីដា ភីអិលស៊ី
រក្សាសិទ្ធិដោយ © ឆ្នាំ២០១៦ វិទ្យាស្ថានស្លឹករឹត | ការចងចាំរបស់ជាតិ | គ្រឹះស្ថានឧត្តមសិក្សាសាធារណៈ នៅក្នុងប្រទេសកម្ពុជា